**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤២....អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំប្រាក់បំណាច់មុខងារប្រចាំខែរបស់**
**ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**
**និងប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្យទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- យោងតាមសំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងរៀបចំផ្តល់ប្រាក់បំណាច់មុខងារបន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់ប្រឆាំងអំពើពុករលួយ និងប្រាក់សោធនប្រចាំខែជូនប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ចំនួនប្រាក់បំណាច់មុខងារបន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់ប្រឆាំងអំពើពុករលួយ និងប្រាក់សោធនប្រចាំខែរបស់ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ។

**មាត្រា៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ។

**មាត្រា៤ .-**

ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ប្រធាន អនុប្រធាននៃអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវទទួលបានប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ. | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ | ៨ ០០០ ០០០ |
| ២ | អនុប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ | ៦ ០០០ ០០០ |
| ៣ | សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ | ៥ ០០០ ០០០ |
| ៤ | ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ | ៦ ០០០ ០០០ |
| ៥ | អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ | ៥ ០០០ ០០០ |

**មាត្រា៥ .-**

ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវទទួលបានប្រាក់បំណាច់មុខងារប្រចាំខែតាមកម្រិត ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| បរិយាយ | កម្រិតប្រាក់បំណាច់មុខងារ(រៀល) | | | | | |
|---|---|---|---|---|---|---|
| | កម្រិតទី៦ | កម្រិតទី៥ | កម្រិតទី៤ | កម្រិតទី៣ | កម្រិតទី២ | កម្រិតទី១ |
| ឧបការី | ៩០០ ០០០ | ៩៣០ ០០០ | ១ ០១០ ០០០ | ២ ៨០០ ០០០ | ៣ ៥០០ ០០០ | ៥ ០០០ ០០០ |

**មាត្រា៦ .-**

ប្រាក់បំណាច់មុខងារប្រចាំខែរបស់ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ តទៅ។

ការកែប្រែប្រាក់បំណាច់មុខងារប្រចាំខែរបស់ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ប្រធាន អនុប្រធាន ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយត្រូវកំណត់ដោយអនុក្រឹត្យ។

ការកំណត់លក្ខខណ្ឌសម្រាប់ការដំឡើងកម្រិតប្រាក់បំណាច់មុខងារជូនឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវរៀបចំដោយប្រធានអង្គភាពប្រឆាំងអំពើពុករលួយ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១៣ រោច ខែ ផល្គុន ឆ្នាំ រកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| | | |
|---|---|---|
| **ទេសរដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** | |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ** | **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** |
| **បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **ឱម យ៉ិនទៀង** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ